# រទេះគោខ្មែរ

បើយើងនិយាយអំពីរទេះគោ ពិតណាស់ថាមនុស្សមួយចំនួនប្រាកដជាស្គាល់ ពិសេសប្រជាកសិករប្រកបរបបធ្វើស្រែចម្ការ ដ្បិតថាប្រទេសខ្មែរជាប្រទេសពឹងផ្អែកលើវិស័យកសិកម្មតាំងពីសម័យដើមមកម្លេះ។ រទេះគោជាទូទៅគេប្រើសម្រាប់ជាយានជំនិះ ឬជាមធ្យោបាយដឹកជញ្ជូនផលិតផលកសិកម្ម ដែលអ្នកស្រុកទាំងឡាយតែងប្រើរទេះគោនេះ ដើម្បីដឹកស្រូវ, កណ្ដាប់, ចំបើង, ថ្នាំជក់ជាដើម និងសម្រាប់ធ្វើដំណើរ និងដឹកសម្ភារៈផ្សេងៗទៅតាមទីជិតឆ្ងាយតាមតម្រូវការ (រូបលេខ១)។



*រូបលេខ១ រទេះគោដឹកកណ្ដាប់*

វត្តមានរទេះគោក្នុងស្រុកខ្មែរ គឺមានតាំងពីសម័យបុរាណមកម្លេះ ដែលខ្មែរចេះប្រើរទេះគោតាមឥណ្ឌាចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជ។ ក្នុងនោះមានសិលាចារឹក K.448 ចារនៅគ.ស៦៧៤ នៃប្រាសាទគុកហ្លួង ខេត្តកំពត មាននិយាយពាក្យ "រទេ្ទហ" ដែលសព្វថ្ងៃសរសេរជា "រទេះ"។ រីឯក្នុងសិលាចារឹកK.720 សតវត្សទី១១ មាននិយាយពាក្យថា "រទេះជើង" និងសិលាចារិក K.158 សតវត្សទី១១មាននិយាយពាក្យថា "រទេះរុង"(រទេះធំ)។ ថ្វីដ្បិតក្នុងសិលាចារឹកមាននិយាយពាក្យថា "រទេះ" តែពុំដឹងថារទេះក្នុងសិលាចារឹកទាំងនោះមានសណ្ឋានរបៀបណា និងអូសដោយមនុស្ស ឬសត្វនោះទេ (គោ ឬសេះ)។ បើមើលចម្លាក់តាមជញ្ជាំងប្រាសាទបុរាណមួយចំនួនក្នុងតំបន់អង្គរ ឧទាហរណ៍ចម្លាក់នៅប្រាសាទបាពួន និងប្រាសាទបាយន្តជាដើម មានបង្ហាញពីចម្លាក់រទេះគោដែលមានទ្រង់ទ្រាយស្រដៀងគ្នាទៅនឹងរទេះគោបច្ចុប្បន្នដែរ ហើយរទេះគោទាំងនោះប្រើជាមធ្យោបាយសម្រាប់ដឹកអីវ៉ាន់ផ្សេងៗ និងធ្វើដំណើរទៅទីឆ្ងាយរបស់អ្នកស្រុកសម័យនោះ(រូបលេខ២-៣)។ ជាមួយគ្នានេះ



*រូបលេខ២ ប្រាសាទបាពួន*



*រូបលេខ៣ ប្រាសាទបាយន្ត*

រទេះគោខ្មែរក៏បានដើរតួនាទីយ៉ាងសំខាន់សម្រាប់វិស័យសង្គមកិច្ច និងជំនឿសាសនាផងដែរ។ បើតាមទស្សនលិទ្ធិព្រហ្មញ្ញសាសនាកង់រទេះ ឬកងច័ក្រ ជាកេតនភ័ណ្ឌរបស់ព្រះនារាយណ៏ និងតំណាងឱ្យខែ ឬឆ្នាំនៃការវិល១ជុំរបស់ព្រះអាទិត្យ គឺ៣៦៥ថ្ងៃ។ រីឯលទ្ធិព្រះពុទ្ធសាសនាក៏មានន័យស្រដៀងគ្នានឹងព្រហ្មញ្ញសាសនាដែរ

គឺជាធម្មចក្រ នៃធម៌វិន័យដែលព្រះពុទ្ធបានសម្ដែង ដោយសព្វថ្ងៃគេប្រើរូបកងច័ក្រ គឺអដ្ឋង្គិមគ្គទាំង៨។ រទេះគោក្នុងស្រុកខ្មែរ មានបង្ហាញជាច្រើនប្រភេទ និងឈ្មោះផ្សេងៗពីគ្នាមានដូចជា រទេះគោត្រីបក រទេះគោចាម្ប រទេះគោឡុកឡាក់



រូបលេខ២៤ រទេះគោចាម្ប



រូបលេខ២៥ រទេះគោសាឡី

រទេះគោកាច់ រទេះគោសាឡី និងរទេះគោមានដំបូលជាដើម ហើយរទេះគោទាំងនោះ សុទ្ធតែមានតួនាទីដឹកសម្ភារៈដូចមានរៀបរាប់នៅខាងលើ(រូបលេខ២៤-៥)[១]។

លុះមកដល់បច្ចុប្បន្នការប្រើរទេះគោបុរាណតាមស្រុកស្រែចម្ការបានបាត់បង់បន្តិចម្ដងៗ ព្រោះវត្ថុមានគ្រឿងចក្រគោយន្តចូលមកស្រុកខ្មែរ ជំនួសការប្រើរទេះគោបុរាណ ហើយម្យ៉ាងទៀត ប្រពៃណីដែលធ្លាប់ប្រើកង់រទេះគោធ្វើពីឈើក៏ជំនួសមកវិញដោយប្រើជាកង់កៅស៊ូ(រូបលេខ២៦)។ ការផ្លាស់ប្ដូរនោះ គឺប្រហែលជាអ្នកស្រុកយល់ថាវត្ថុទាំងនោះមានភាពងាយស្រួលប្រើជាងរទេះគោបុរាណ ហើយអាចប្រើបានពេលយូរអង្វែងជាងក៏ថាបាន។ ការប្រើប្រាស់រទេះគោបុរាណពិតមែនតែមានការថយចុះ ប៉ុន្តែយើងនៅឃើញមានប្រពៃណីប្រណាំង



រូបលេខ២៦ រទេះគោដឹកប្រើកង់កៅស៊ូ

រទេះគោដែលជាល្បែងប្រជាប្រិយរបស់ខ្មែរនៅមានបន្តជាហូរហែមកដល់សព្វថ្ងៃនេះ គឺតាមបណ្ដាក្រុង និងខេត្តមួយចំនួនក្នុងស្រុកខ្មែរ ដែលជាទូទៅគេនិយមប្រារព្ធក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ(រូបលេខ២៧)។ ក្រៅពីនោះ រទេះគោបុរាណក៏មានការពេញនិយមសម្រាប់ដឹកភ្ញៀវទេសចរនៅតាមតំបន់ទេចរណ៍បែបវប្បធម៌ និងធម្មជាតិនៃតំបន់សហគមន៍មួយចំនួនក្នុងស្រុកខ្មែរ ឧទាហរណ៍តំបន់ទេសចរណ៍វប្បធម៌សៀមរាបអង្គរ និងតំបន់ទេសចរណ៍ធម្មជាតិចំប៉ក់ខេត្តកំពង់ស្ពឺជាដើម(រូបលេខ២៨)។ ទាំងនេះ គឺជាប្រភពចំណូលមួយជួយលើកតម្កើងជីវភាព



រូបលេខ២៧ ប្រណាំងរទេះគោ



រូបលេខ២៨ រទេះគោដឹកភ្ញៀវទេចរ

[១] កែម សុនីន, ២០០៩, មធ្យោបាយដឹកជញ្ជូនក្នុងសង្គមខ្មែរ, រ៉េយំ, ភ្នំពេញ

រស់នៅរបស់អ្នកស្រុក ក្រៅតែពីការធ្វើស្រែចម្ការដែលជាមុខរបរប្រពៃណីរបស់ពួកគាត់។ ក្នុងនោះរទេះគោបុរាណក៏មានបង្ហាញជាគ្រឿងតាំងលម្អក្នុងភូមិគ្រឹះ ឬតាមផ្ទះបុរាណ ភោជនីយដ្ឋាន និងតាមសណ្ឋាគារធំៗជាដើម ដ្បិតអ្នកមានធនធាននៃម្ចាស់ទីតាំងទាំងនោះ មានគំនិតចង់រចនា និងច្នៃប្រឌិតទីតាំងរបស់ខ្លួនឱ្យដូចជាកន្លែងបុរាណ(រូបលេខ៩-១០)។



*រូបលេខ៩ រទេះគោជាគ្រឿងលម្អ*



*រូបលេខ១០ រទេះគោជាគ្រឿងលម្អ*

Khmer Civilization

*អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ*